សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**សារលិខិត**

**របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**
**អបអរសាទរពិធីបុណ្យសមុទ្រឆ្នាំ២០១៨ ក្រោមប្រធានបទ "ឆ្នេរស្អាត ពលរដ្ឋរមណីយ"**
**អមដោយពាក្យស្លោក "អេកូទេសចរណ៍សម្រាប់កំណើនបៃតង និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព"**
**ពីថ្ងៃសុក្រ ៧កើត ដល់ថ្ងៃអាទិត្យ ៩កើត ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២**
**ត្រូវនឹងថ្ងៃទី ១៤-១៦ ខែ ធ្នូ ឆ្នាំ ២០១៨ នៅខេត្តកោះកុង**

*- ជនរួមជាតិទាំងអស់ជាទីមេត្រី !*

កម្ពុជាបច្ចុប្បន្នមានសុខសន្តិភាព ស្ថិរភាពនយោបាយ សុវត្ថិភាពពេញលេញ សណ្តាប់ធ្នាប់ល្អប្រពៃ បរិបូរណ៍ ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធល្អប្រសើរ និងមានការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យ និងជាគោលដៅទេសចរណ៍ល់ដាប់ពិភពលោក ប្រកបដោយក្តីសង្ឃឹមឆ្ពោះទៅរកអនាគតមួយដ៏រុងរឿង និងត្រចះត្រចង់ ដែលជាកត្តាធានាដល់ការរស់នៅរបស់ប្រជាជន ប្រកបដោយសេចក្តីសុខសុភមង្គលក្នុងភាពសុខដុមរមនា និងមានជីវភាពរស់នៅកាន់តែប្រសើរ។ រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកវិស័យទេសចរណ៍ជាវិស័យអាទិភាពជា **"មាសបៃតង"** រួមចំណែកយ៉ាងសំខាន់ដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ តាមរយៈការបង្កើត និងបង្កើនឱកាសការងារ បង្កើនប្រាក់ចំណូលជូនប្រជាពលរដ្ឋដោយផ្ទាល់ និងដោយប្រយោល ជំរុញការនាំចេញនៅនឹងកន្លែង ទ្រទ្រង់កំណើនសេដ្ឋកិច្ច បង្កើនចំណូលជាតិ ចូលរួមដល់ការកាត់បន្ថយភាពក្រីក្រ ពិសេសចូលរួមជួយដល់ការអភិវឌ្ឍ និងការថែរក្សាការពារបរិស្ថាន ធនធានធម្មជាតិ និងវប្បធម៌ប្រពៃណីរបស់យើង ប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់។

ជាមួយគ្នានេះ វិស័យទេសចរណ៍បានចូលរួមលើកកម្ពស់នូវកិត្យានុភាពនៃព្រះរាជាណាចក្រកម្ពុជាលើឆាកអន្តរជាតិផងដែរ។ ជាក់ស្តែងក្នុងឆ្នាំ២០១៧ ក្រុមប្រឹក្សាពាណិជ្ជកម្ម និងទេសចរណ៍អឺរ៉ុប បានបោះឆ្នោតជ្រើសរើស **"រាជធានីភ្នំពេញជារាជធានីវប្បធម៌ និងទេសចរណ៍ពិភពលោក"** ហើយប្រាសាទអង្គរវត្តរបស់កម្ពុជាបន្តជាប់ **"ចំណាត់ថ្នាក់លេខ១ ជាសំណង់ប្រវត្តិសាស្ត្រដ៏អស្ចារ្យបំផុតលើពិភពលោក ឆ្នាំ២០១៨"** ពីទីភ្នាក់ងារប្រឹក្សាយោបល់ក្នុងការធ្វើដំណើរពិភពលោក ( Trip Advisor ) ដែលនេះពិតជាបានឆ្លុះបញ្ចាំងយ៉ាងប្រត្យក្សពីភាពល្បីល្បាញ និងការទទួលស្គាល់យ៉ាងច្បាស់ពីសំណាក់ទេសចររាប់លាននាក់មកលើគោលដៅទេសចរណ៍របស់កម្ពុជានាពេលបច្ចុប្បន្ន និងអរិយភាពរបស់កម្ពុជាជាគោលដៅទេសចរណ៍ **"វប្បធម៌ និងធម្មជាតិ"** ហើយកម្ពុជាបាននិងកំពុងក្លាយជាបេះដូង និងគោលដៅទេសចរណ៍ដ៏ទាក់ទាញនៃតំបន់អាស៊ីអាគ្នេយ៍។

ចាប់ពីឆ្នាំ២០១១មក **តំបន់ឆ្នេរសមុទ្រកម្ពុជា** បានក្លាយជាសមាជិកក្លឹបឆ្នេរសមុទ្រដែលស្អាតបំផុតលើសាកលលោក ហើយកិត្តិនាមនេះបាននិងកំពុងរួមចំណែកយ៉ាងសកម្មក្នុងការធ្វើឱ្យកម្ពុជាក្លាយជាគោលដៅទេសចរណ៍ប្រកបដោយឧត្តមភាព និងភាពទាក់ទាញខ្ពស់ ចូលរួមចំណែកសម្រេចចក្ខុវិស័យអាស៊ានជា

គោលដៅទេសចរណ៍លំដាប់ពិភពលោក និងប្រកបដោយភាពកក់ក្ដៅ "ASEAN: the World-Class Destination" និង "ASEAN: Feel the Warmth"។ តំបន់ឆ្នេរកម្ពុជាបាននិងកំពុងដើរតួនាទីយ៉ាងសំខាន់ជាប៉ូលសេដ្ឋកិច្ចក្នុងការទាក់ទាញការវិនិយោគសម្រាប់ជំរុញកំណើនសេដ្ឋកិច្ចជាតិ និងត្រូវបានចាត់ទុកថាជាគោលដៅទេសចរណ៍ដ៏មានភាពទាក់ទាញ និងប្រកបដោយភាពប្រកួតប្រជែងខ្ពស់នៅកម្ពុជា និងក្នុងតំបន់ ដោយតំបន់កោះមួយចំនួនក៏កំពុងធ្វើការអភិវឌ្ឍឱ្យក្លាយទៅជារមណីយដ្ឋានទេសចរណ៍ (Tourism Resort) ដែលមានផលិតផល និងសេវាកម្មកម្រិតស្តង់ដាអន្តរជាតិ គួបផ្សំនឹងហេដ្ឋារចនាសម្ព័ន្ធដ៏សម្បូរបែបទាំងផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាស។

ក្នុងបរិបទនេះ រាជរដ្ឋាភិបាលបានកំណត់ប្រារព្ធពិធីបុណ្យសមុទ្រ ដែលមិនត្រឹមតែចូលរួមចំណែកក្នុងការផ្សព្វផ្សាយពីសក្ដានុពលទេសចរណ៍នៃខេត្តតំបន់ឆ្នេរសមុទ្រប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចូលរួមគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ **"ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធិភាព៖ កសាងមូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០"** ដោយផ្តោតការយកចិត្តទុកដាក់អភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាព និងការទទួលខុសត្រូវ ឈរលើការប្តេជ្ញាចិត្តរួមមួយច្បាស់លាស់ក្នុងការរក្សាតុល្យភាពរវាងផលប្រយោជន៍សេដ្ឋកិច្ច សង្គម បរិស្ថាន និងវប្បធម៌ប្រជាពលរដ្ឋមូលដ្ឋាន ដូចដែលត្រូវបានឆ្លុះបញ្ចាំងតាមរយៈប្រធានបទនៃពិធីបុណ្យសមុទ្រ លើកទី៧ ឆ្នាំ២០១៨ នៅខេត្តកោះកុង ដែលជាខេត្តអេកូទេសចរណ៍មួយដ៏ស្រស់ស្អាតនៅភូមិភាគនិរតីនៃប្រទេសកម្ពុជា គឺ **"ឆ្នេរស្អាត ពលរដ្ឋរមណីយ"** (Beautiful Bay, Happy Citizen) អមដោយពាក្យស្លោក **"អេកូទេសចរណ៍សម្រាប់កំណើនបៃតង និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព** ( Ecotourism for Green Growth and Sustainable Development)។ ទន្ទឹមនឹងនេះ ព្រឹត្តិការណ៍នេះ ក៏ជាឱកាសមួយដើម្បីពង្រឹងគុណភាពឧស្សាហកម្មទេសចរណ៍ ជំរុញការបង្កើត និងអភិវឌ្ឍផលិតផលទេសចរណ៍ថ្មីៗប្រកបដោយភាពច្នៃប្រឌិត និងការទទួលខុសត្រូវខ្ពស់ ឱ្យស្របទៅនឹងសក្ដានុពលធនធានធម្មជាតិនៅតំបន់ឆ្នេរសមុទ្រកម្ពុជាដែលត្រូវបានប្រសិទ្ធនាមថាជា **"តារានៃទិសនិរតី"** (The Rising Star of the Southwest)។

ឈរលើមូលដ្ឋាននៃការអភិវឌ្ឍ និងកំណើនដ៏គំហុកនេះ ក៏ទាមទារឱ្យមានការគិតគូរ និងគ្រប់គ្រងដោយហ្មត់ចត់ ដោយត្រូវមានផែនការអភិវឌ្ឍ និងគ្រប់គ្រងទេសចរណ៍គ្រប់ជ្រុងជ្រោយ ពិសេសស្របពេលដែលពិភពលោកទាំងមូលបាននិងកំពុងប្រឈមនឹងការវិវត្តថ្មីៗឥតឈប់ឈរ ទាំងលើមូលដ្ឋានសេដ្ឋកិច្ច សង្គម និងបរិស្ថាន ដែលស្តែងឡើងតាមរយៈការប្រែប្រួលជាច្រើន ដូចជាភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចសកលលោក បញ្ហាគ្រោះធម្មជាតិកើតឡើងជាបន្តបន្ទាប់ មានជាអាទិ៍ ការកើនឡើងកំដៅភពផែនដី ការប្រែប្រួលអាកាសធាតុ បញ្ហាជំងឺឆ្លងជាដើម។ ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមទាំងនេះ ការយកចិត្តទុកដាក់ដល់ទស្សនទាននៃ**ភាពស្អាត និងបៃតង** គឺពិតជាមានភាពចាំបាច់ ខណៈពេលដែលពិភពលោកទាំងមូលកំពុងបោះជំហានទៅមុខនៅក្នុងសម័យកាលបៃតង។ ផ្អែកលើទស្សនទាននេះ ការអភិវឌ្ឍទេសចរណ៍តំបន់ឆ្នេរទាមទារចាំបាច់ឱ្យមានការ**អភិវឌ្ឍទីក្រុងស្អាត/ទីក្រុងបៃតង ឆ្នេរស្អាត និងកោះស្អាត និងបៃតង** ដែលជាគំរូអភិវឌ្ឍន៍គិតគូរដល់ការអភិរក្ស ថែរក្សាសម្បត្តិវប្បធម៌ ធនធានធម្មជាតិ និងបរិស្ថានប្រកបដោយនិរន្តរភាព ពោលគឺ **អភិវឌ្ឍ ដើម្បីអភិរក្ស** ដោយត្រូវធានាឱ្យបាននូវនិរន្តរភាព និងតុល្យភាពខាងផ្នែកសេដ្ឋកិច្ច សង្គម វប្បធម៌ និងបរិស្ថាន។ ក្នុងន័យនេះ ទីក្រុងជាប់ឆ្នេរត្រូវតែជា**ទីក្រុងបៃតង/ទីក្រុងស្អាត** ពោលជាទីក្រុងដែលមានបរិស្ថាន អនាម័យ សណ្តាប់ធ្នាប់ល្អ គួបផ្សំនឹងហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់គ្រប់គ្រាន់ដែលផ្តល់នូវភាពកក់ក្តៅ និងមជ្ឈដ្ឋានរស់នៅល្អប្រសើរដល់ប្រជាជនក្នុងទីក្រុង និងភ្ញៀវទេសចរ ពីព្រោះថាការ**អភិវឌ្ឍទីក្រុងតំបន់ឆ្នេរឱ្យក្លាយជាទីក្រុងបៃតង** មិនត្រឹមតែកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមានដល់និរន្តរភាពនៃធនធានតំបន់

ឆ្នេរប៉ុណ្ណោះទេ តែថែមទាំងជួយបង្កើនភាពទាក់ទាញភ្ញៀវទេសចរឱ្យមកទស្សនា និងកំសាន្តនៅតំបន់ឆ្នេរកាន់តែច្រើនថែមទៀតផង។

ក្នុងន័យនេះយើងចាំបាច់ត្រូវរួមគ្នា "រួមគិត រួមធ្វើ រួមទទួលខុសត្រូវ" ក្នុងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជាឱ្យមាននិរន្តរភាព បរិយាប័ន្ន ប្រកបដោយការទទួលខុសត្រូវលើគ្រប់វិស័យសេដ្ឋកិច្ច សង្គម ស័ក្តិសមជា "**ឆ្នេរសមុទ្រកម្ពុជាៈ តារារះនាទិសនិរតី**"។

ឆ្លៀតក្នុងឱកាសពិធីដ៏វិសេសវិសាលនេះ ខ្ញុំសូមអំពាវនាវដល់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ បងប្អូនជនរួមជាតិទាំងអស់ វិស័យឯកជន អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍចូលរួមឱ្យបានផុសផុលប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ក្នុងការអភិវឌ្ឍ និងអភិរក្សតំបន់ឆ្នេរសមុទ្រកម្ពុជា។ លើសពីនេះទៀត ខ្ញុំក៏សូមអំពាវនាវដល់ប្រតិបត្តិករទេសចរណ៍ ទេសចរជាតិ និងអន្តរជាតិ អាជ្ញាធរមូលដ្ឋាន និងបងប្អូនប្រជាពលរដ្ឋចូលរួមឱ្យកាន់តែសកម្មចលនាប្រឡងប្រណាំង "**ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ**" និងសហការថែរក្សាសោភ័ណភាព អនាម័យ បរិស្ថាន ដែលជាកត្តាចម្បង ដែលមិនអាចខ្វះបានក្នុងការថែរក្សាតំបន់ឆ្នេរសមុទ្រឱ្យស្រស់ស្អាតគង់វង្សយូរអង្វែង ដើម្បីទុកជាមរតកដល់កូនចៅជំនាន់ក្រោយ។

ខ្ញុំមានសង្ឃឹមយ៉ាងមុតមាំថា ការប្រារព្ធពិធីបុណ្យសមុទ្រជារៀងរាល់ឆ្នាំ គឺជាកាលានុវត្តភាពដ៏ប្រសើរសម្រាប់កម្ពុជា ក្នុងការធ្វើឱ្យឆ្នេរសមុទ្រកម្ពុជាក្លាយជាគោលដៅទេសចរណ៍ប្រកបដោយគុណភាព ដែលជាកត្តាចូលរួមចំណែកក្នុងការផ្តល់ចំណូលដោយផ្ទាល់ ការបង្កើនការងារ ការចូលរួមកាត់បន្ថយភាពក្រីក្រ និងការការពារបរិស្ថាន ធនធានធម្មជាតិ ជូនដល់ប្រជាពលរដ្ឋក្នុងតំបន់ឆ្នេរ ពិសេសចូលរួមចំណែកធ្វើឱ្យសម្រេចបាននូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០៣០ របស់អង្គការសហប្រជាជាតិ ព្រមទាំងបង្កើនស្មារតីស្រឡាញ់ជាតិមាតុភូមិ សាមគ្គីភាព និងមិត្តភាពផងដែរ។

ខ្ញុំក៏សូមយកឱកាសនេះ សូមអញ្ជើញភ្ញៀវអន្តរជាតិពីគ្រប់ទិសទីមកទស្សនាកំសាន្តនៅព្រះរាជាណាចក្រកម្ពុជា ជាពិសេសតំបន់ឆ្នេរសមុទ្រកម្ពុជា និងសូមអំពាវនាវដល់ជនរួមជាតិឱ្យចូលរួមគាំទ្រសកម្មភាពទេសចរណ៍ ដោយអញ្ជើញធ្វើដំណើរកំសាន្តទស្សនាតំបន់ទេសចរណ៍នានានៅទូទាំងប្រទេស ដើម្បីចូលរួមចំណែកជំរុញការអភិវឌ្ឍវិស័យទេសចរណ៍ ជំរុញសកម្មភាពផ្ទៃក្នុងផង និងបង្កើនការស្រលាញ់ជាតិមាតុភូមិ សាមគ្គីភាព មិត្តភាព និងចែករំលែកផលប្រយោជន៍ជូនដល់ប្រជាជននៅមូលដ្ឋានផង។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរឱ្យការប្រារព្ធពិធីបុណ្យសមុទ្រ នាឆ្នាំ២០១៨នេះ ប្រព្រឹត្តទៅយ៉ាងអធិកអធម និងប្រកបដោយភាពសប្បាយរីករាយ និងសូមជូនពរដល់បងប្អូនជនរួមជាតិទាំងអស់ សូមទទួលបាននូវសិរីសួស្តី ជ័យមង្គល និងវិបុលសុខជារៀងដរាបតរៀងទៅ៕

ថ្ងៃព្រហស្បតិ៍ ១កើត ខែ កត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ២០១៨

**ហ៊ុន សែន**